មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

Centre for Peace and Development (CPD)

Cambodia Development Resource Institute (CDRI)


# កំណត់ហេតុកិច្ចប្រជុំខប់សែលប្រ៉ែម តំបន់ទី ៨

## យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

ថ្ងៃច័ន្ទ ទី២៦ ខែមីនា ឆ្នាំ២០០៧

ខេត្តកំពង់ធំ

**ខប់សែល ដំណាក់កាលទី ២**

**COPCEL Phase II**


*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

## របៀបវារៈនៃកិច្ចប្រជុំ

០១.ចំណាប់អារម្មណ៍ស្វាគមន៍ដោយ លោក **ឡារី ស្រ្តេន្ទ (Larry Strange)** នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

០២.បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ូម (COPCELPROM) ដោយលោក **ឱក សេរី សោភក្តិ៍** ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI

០៣.ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយ លោក **ប្រែង សារុធ** ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តកំពង់ធំ

០៤. មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទខេត្តកំពង់ធំ

០៥. សេចក្តីផ្សេងៗ

**១. ចំណាប់អារម្មណ៍ស្វាគមន៍ដោយ លោក ឡារី ស្រ្តេន្ទ (Larry Strange) នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (CDRI)

លោក **ឡារី ស្រ្តេន្ទ** នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI បានធ្វើការស្វាគមន៍ និងថ្លែងអំណរគុណដល់សមាជិកនៃអង្គប្រជុំទាំងមូល ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំនេះ ។ លោក សូមថ្លែងអំណរគុណដល់ ឯកឧត្តម ណាន សុខ អភិបាលខេត្តកំពង់ធំ ដែលបានគាំទ្រយ៉ាងពេញទំហឹង និងជួយសំរួលរាល់ការងាររបស់វិទ្យាស្ថាន CDRI ដើម្បីឱ្យមានការរៀបចំកិច្ចប្រជុំនេះឡើង ហើយលោកក៏សូមថ្លែងអំណរគុណផងដែរចំពោះ លោក **ប្រែង សារុធ** ប្រធានគណកម្មាធិការរៀបចំការបោះឆ្នោតខេត្តកំពង់ធំ ដែល លោក នឹងធ្វើការរាយការណ៍អំពីស្ថានភាពនានាជុំវិញដំណើការរៀបចំការបោះឆ្នោត ក្នុងបរិបទខេត្តកំពង់ធំ ។ លោក បានលើកឡើងថា វិទ្យាស្ថាន CDRI គឺជាវិទ្យាស្ថានឯករាជមួយដែលនាំមុខគេនៅក្នុងប្រទេសកម្ពុជា ដែលបានធ្វើការសិក្សាស្រាវជ្រាវទៅលើគោលនយោបាយអភិវឌ្ឍន៍សំខាន់ៗមួយចំនួនដូចជា ការងារអភិវឌ្ឍន៍សេដ្ឋកិច្ច និងពាណិជ្ជកម្មនៅក្នុងតំបន់ អភិបាលកិច្ច និងកំណែទំរង់រដ្ឋបាលសាធារណៈ ការគ្រប់គ្រងធម្មជាតិ ការកាត់បន្ថយភាពក្រីក្រ និងការកសាងសិន្តភាព ។ វិទ្យាស្ថាន CDRI មានឆន្ទៈយ៉ាងមុតមាំក្នុងការចូលរួមលើកស្ទួយអោយមានលទ្ធិប្រជាធិបតេយ្យជាបណ្តើរនៅក្នុងប្រទេសកម្ពុជា ។ វិទ្យាស្ថាន CDRI យល់ថា យន្តការនៃការបោះឆ្នោត គឺជាវិសាលភាពមួយដែលនាំអោយយើងទទួលបានលទ្ធិប្រជាធិបតេយ្យពិតប្រាកដនៅក្នុងប្រទេសកម្ពុជាយើងនេះ ដូចនេះយន្តការខប់សែលប្រ៉ូមបង្កើតឡើងដើម្បីរួមចំណែកក្នុងការជំរុញ និងធ្វើអោយកាន់តែប្រសើឡើងនូវដំណើការបោះឆ្នោត ។ លោក បានកោតសរសើរអំពីលទ្ធផលនៃការពិភាក្សាប្រកបទៅដោយការយោគយល់គ្នាក្នុងពេលពិភាក្សាទាំងក្នុងថ្នាក់ជាតិ និងថ្នាក់ខេត្ត លោក សុំថ្លែងអំណរគុណចំពោះស្ថាប័នពាក់ព័ន្ធទាំងអស់ ជាពិសេសក្រសួងមហាផ្ទៃ គណកម្មធិការជាតិរៀបចំការបោះឆ្នោត គណកម្មខេត្តរៀបចំការបោះឆ្នោត តំណាងគណបក្សនយោបាយ អង្គការសង្គមស៊ីវិល ឯកឧត្តមអភិខេត្ត អភិបាលរងខេត្ត អភិបាលស្រុក និងក្រុមប្រឹក្សាឃុំ ដែលបានចូលរួមពិភាក្សាយ៉ាងស្វិតស្វាញក្នុងកិច្ចប្រជុំម្តងៗ ។ លោក បានថ្លែងអំណរគុណចំពោះ UNDP ដែលបានគាំទ្រកម្មវិធី ខប់សែល តាំងពីថ្នាក់ខេត្តរហូតដល់ថ្នាក់ជាតិ ។

**០២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ូម** (COPCELPROM) **ដោយលោក ឱក សេរី សោភក្តិ៍ ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន** CDRI

លោក **ឱក សេរី សោភក្តិ៍** បានលើកឡើងពីប្រវត្តិដើមទាក់ទង នឹងយន្តការខប់សែល ។ ដែលពេលនោះ លោក ក៏បានចូលរួមតស៊ូ នឹងសង្គ្រាមនេះដែរនៅតាមជាយដែន ក្រោយពីប្រទេសកម្ពុជាទទួលរងនូវសង្គ្រាមអស់រយៈពេល ២៨ឆ្នាំ ដែលធ្វើអោយប្រទេសកម្ពុជារងនូវការខូចខាតយ៉ាងច្រើន ។ នៅពេលបោះឆ្នោតដែលរៀបចំដោយ UN នៅឆ្នាំ ១៩៩៣ ដោយមានការស្នើពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងឯកឧត្តម ស ខេង ឱ្យចូលរួមនៅក្នុងរាជរដ្ឋាភិបាល លោក ក៏បានធ្វើជាទីប្រឹក្សា និងជានាយខុទ្ទកាល័យរបស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ១៩៩៨ ។ លោក បានទទួលការងាររៀបចំការបោះឆ្នោតនៅឆ្នាំ ១៩៩៨ ដោយ លោក បានរៀបចំជាមួយប្រទេសមួយចំនួន ដើម្បីរៀបចំការបោះឆ្នោតដោយខ្មែរខ្លួនឯង ។ យើងចាប់ផ្តើមនៅឆ្នាំ ១៩៩៤ ដោយមានការចូលរួមយ៉ាងសស្រាក់សស្រាំ រហូតដល់មានបញ្ហានៅឆ្នាំ ១៩៩៧ សឹងតែធ្វើឱ្យយន្តការនៅឆ្នាំ ១៩៩៨ ពិបាកដំណើរការ ប៉ុន្តែយើងនៅតែជំនះធ្វើឱ្យទាល់តែបាន ។ ពេលនោះដែរ លោក គិតថា ការបោះឆ្នោតដែលពោរពេញទៅដោយទំនាស់ គឺនៅពេលណាមួយយើងត្រូវតែអាចដោះស្រាយទំនាស់នៅក្នុងការបោះឆ្នោតនៅប្រទេសកម្ពុជាបានដោយខ្មែរខ្លួនឯង ។ លោក បានចំណាយពេល ៥ឆ្នាំ ក្នុងការធ្វើការនោះ នៅក្នុងរយៈពេល ៥ឆ្នាំ នោះរាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចរៀបចំការបោះឆ្នោតឆ្នាំ ១៩៩៨ ដើម្បីរៀបចំការបោះឆ្នោតដោយខ្លួនឯង ។ យើងចាប់ផ្តើមរៀបចំការបោះឆ្នោតនេះតាំងពីឆ្នាំ ១៩៩៤ មកម្លេះ មួយឆ្នាំ គឺក្រោយពេលដែលអ៊ុនតាក់រៀបចំឱ្យ យើងបានរៀបចំភ្លាមដោយសារយើងត្រូវរៀនសូត្រច្រើនណាស់អំពីការបោះឆ្នោត ទីបំផុតយើងក៏បានឈានទៅរកការបោះឆ្នោត ឆ្នាំ១៩៩៨ ពេលនោះដែរ លោក គិតថា ការបោះឆ្នោតដែលពោរពេញទៅដោយទំនាស់នេះ គឺនៅពេលណាមួយយើងត្រូវតែអាចដោះស្រាយទំនាស់នៅក្នុងការបោះឆ្នោតនៅប្រទេសកម្ពុជាបានដោយខ្មែរខ្លួនឯង ។

នៅឆ្នាំ ១៩៩៩ លោក គិតថា រយៈពេល ៥ឆ្នាំ ធ្វើការជាមួយរដ្ឋ ៥ឆ្នាំធ្វើការក្រៅរដ្ឋ ៥ឆ្នាំធ្វើការជាទីប្រឹក្សាឱ្យអង្គការអន្តរជាតិធំៗ លោក ក៏បានលាលែង ពីដំណែងក្នុងជួររដ្ឋាភិបាល ។ នៅពេលដែល លោក ចាក់ចេញពីជួររដ្ឋាភិបាលទៅ លោក បានធ្វើការឱ្យវិទ្យាស្ថាន CDRI ក្នុងឋានៈជាអ្នកសម្របសម្រួលក្នុងកម្មវិធីដើម្បីអភិវឌ្ឍន៍ និងសន្តិភាព នៅពេលនោះ លោក បានធ្វើការស្រាវជ្រាវមួយថា តើការបោះឆ្នោតឆ្នាំ ១៩៩៨ ហេតុអ្វីបានជាមានអំពើហិង្សាយ៉ាងច្រើនកើតឡើង? ហើយក្នុងឆ្នាំ ១៩៩៩ នេះដែរ លោក ក៏បានគិតឃើញបង្កើតយុទ្ធនាការ ខបសែល នេះឡើង ដែលជាយន្តការបង្ការទំនាស់ ដោយអញ្ជើញគ្រប់គូភាគីពាក់ព័ន្ធ នឹងការបោះឆ្នោតទាំងអស់យកមកជជែកគ្នាត្រង់ទៅ ត្រង់មកបង្កើតនូវបរិយាកាសទំនុកចិត្តគ្នាមួយ ហើយបង្កើតវប្បធម៌មួយដែលជជែកគ្នាត្រង់ទៅត្រង់មកដោយអហឹង្សា ។ លោក បានបន្តទៀតថា ការប្រជុំនៅថ្នាក់ជាតិជាការល្អប្រសើរហើយ ប៉ុន្តែទំនាស់ពិតប្រាកដដែលសំខាន់ គឺកើតឡើងនៅថ្នាក់មូលដ្ឋាន បើសិនយើងក្តាប់ ឬគ្រប់គ្រងទំនាស់ទាំងអស់នេះបាន ជាពិសេស នៅថ្នាក់ភូមិ ឃុំ រឿងទាំងអស់មិនបណ្តាលឱ្យមានទំនាស់ដល់ថ្នាក់លើទេ ។ ដោយមើលឃើញពីសារៈសំខាន់នេះ ទើប ខប់សែល បង្កើតអោយមាន ខប់សែលប្រ៊មនេះឡើង ដែលបានទាញយកវប្បធម៌នៃការជជែកពិភាក្សាគ្នាពីថ្នាក់ជាតិទៅថ្នាក់ខេត្ត ដែលយើងមានការចូលរួមជាពិសេសពីឃុំដែលតំណាងឱ្យគណបក្សនិមួយៗចំនួន ១២នាក់ មកចូលរួមគ្រប់ខេត្តទាំងអស់មានទាំងមេភូមិ សង្គមស៊ីវិល និងប្រធានមន្ទីរដែលបានចូលរួមផងដែរ ហេតុដូចនេះហើយទើប យន្តការខប់សែលប្រ៊ម បានចាប់កំណើតឡើង ។ លោក បានបន្តថា យន្តការខប់សែលប្រ៊ម និងខប់សែលនៅថ្នាក់ជាតិ មានគោលដៅធំៗ៣:

**ទី១** ជួយ គ.ជ.ប និង រាជរដ្ឋាភិបាលជាពិសេសក្រសួងមហាផ្ទៃធ្វើយ៉ាងណាធ្វើឱ្យការពិនិត្យនិងការចុះឈ្មោះបោះឆ្នោតឱ្យក្លាយជាទម្លាប់របស់ប្រជាពលរដ្ឋកម្ពុជា ឱ្យតែដល់ពេលបោះឆ្នោតប្រជាពលរដ្ឋដែលមានអាយុគ្រប់ ១៨ឆ្នាំ ទៅសាលាឃុំដើម្បីចុះឈ្មោះបោះឆ្នោត និងដើម្បីមើលឈ្មោះរបស់ពួកគេតើមាន ឬអត់ ។ ម្យ៉ាងវិញទៀតរឿងសរសេរឈ្មោះត្រូវសរសេរឱ្យមានលក្ខណៈ

ត្រឹមត្រូវ និងឈប់ដូរឈ្មោះទៀតទៅពេលដែលចុះទៅតាមឃុំមានការលំបាកដោយសារតែប្រជាពលរដ្ឋ លោក ដូរឈ្មោះច្រើន សំបុត្រកំណើតខុសពីអត្តសញ្ញាណប័ណ្ណ អត្តសញ្ញាណប័ណ្ណខុសពីឈ្មោះអត្រានុកូលដ្ឋាន ។ ដូច្នេះយើងត្រូវបង្ហាត់ប្រជាពលរដ្ឋយើងឱ្យឈប់ប្រើវិធីនេះទៀតទៅ និងគ្រប់តំណាងរដ្ឋបាលនៅគ្រប់ជាន់ថ្នាក់នៅពេលដែលសរសេរឈ្មោះពីមុនយើងឃើញថា មានការសរសេរខុសច្រើនស្ទើរតែគ្រប់ជាន់ថ្នាក់ ឥលូវនេះយើងកំពុងតែធ្វើការកែតម្រូវបានហើយ ហើយ UNDP កំពុងតែរកវិធីជួយរដ្ឋាភិបាលព្រោះឈ្មោះស្ទួនច្រើន អញ្ចឹងយើងធ្វើយ៉ាងណាលុបបំបាត់ឈ្មោះស្ទួនដែលមានរាប់សែននាក់នោះចោល ។

**ទី២** ដោយសារតែច្បាប់បោះឆ្នោតលើកនេះបានចែងថា មានតែអត្តសញ្ញាណប័ណ្ណទើបអាចបោះឆ្នោតបាន ដូច្នេះបានជាខប់សែល បានធ្វើការជាមួយក្រសួងមហាផ្ទៃដើម្បីសូមធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋខ្មែរដែលមានអាយុ ១៨ឆ្នាំ បានទទួលអត្តសញ្ញាណប័ណ្ណគ្រប់ៗគ្នា និងបានទទួលដោយរាជរដ្ឋាភិបាលប្រកាសជាសាធារណៈកុំឱ្យមានអស់លុយអស់កាក់ ដូច្នេះហើយបានជា ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **ស ខេង** លោក បានបើកយុទ្ធនាការឆ្នាំ ២០០៦ ជាយុទ្ធនាការគំហុគមួយ គឺក្នុង ១ឆ្នាំធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋដែលមិនទាន់បានទទួលអត្តសញ្ញាណប័ណ្ណ ១លាន៩សែននាក់សូមឱ្យបានទទួលទាំងអស់គ្នា ។ តាមខប់សែល ដឹងលទ្ធផលទោះមិនបាន ១០០% ក៏ ៩៥% នៃប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសដែលមានអាយុចាប់ពី ១៨ឆ្នាំ ឡើង គឺបានទទួលអត្តសញ្ញាណប័ណ្ណគ្រប់គ្នា ហើយយើងគិតថា ក្នុងតែមួយឆ្នាំ ២០០៧ នេះទៀត នឹងធ្វើយ៉ាងណារួមគ្នាជាមួយ និង NEC វិទ្យាស្ថាន CDRI និងក្រសួងមហាផ្ទៃ ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរមានអត្តសញ្ញាណប័ណ្ណគ្រប់ៗគ្នាតែម្តង ។ បន្ទាប់មកយើង នឹងធ្វើការអប់រំដល់ប្រជាពលរដ្ឋរបស់យើងសូមអង្វរ លោក ឱ្យឈប់ដូរឈ្មោះទៅព្រោះដល់ពេលទៅធ្វើអត្តសញ្ញាណប័ណ្ណដាក់ឈ្មោះផ្សេងនាំឱ្យអាជ្ញាធរខេត្ត, ស្រុកវង្វេងវង្វាន់អស់ហើយ សូមឱ្យយើងមានការប្រយ័ត្ននូវអក្ខរាវិរុទ្ធឈ្មោះរបស់យើង ព្រោះកន្លងមកយើងមិនសូវយកចិត្តទុកដាក់ទេចំពោះបញ្ហាហ្នឹង ។ ដូច្នេះ ខប់សែល សង្ឃឹមថា ប៉ុន្មានឆ្នាំទៅមុខទៀតបញ្ហាអត្តសញ្ញាណប័ណ្ណលែងចោទជាបញ្ហាទៀតនៅក្នុងប្រទេសកម្ពុជាយើង ព្រោះនៅក្នុងប្រទេសនីមួយៗពេលយើងកើតជាពលរដ្ឋដល់អាយុ ១៨ឆ្នាំ បញ្ហាអត្តសញ្ញាណប័ណ្ណគឺជាបញ្ហាមូលដ្ឋានតែម្តង កាលណាគ្មានអត្តសញ្ញាណប័ណ្ណយើងមិនអាចរៀន, ធ្វើការ, បើកលុយ ឬធ្វើអ្វីផ្សេងៗទៀតបានទេ វាហាក់ដូចជាយើងគ្មានរូបនៅក្នុងទឹកដីនោះអញ្ចឹង ដូច្នេះហើយបានជាយើងជុំរុញបញ្ហាហ្នឹងសំខាន់ណាស់ដើម្បីឱ្យប្រជាពលរដ្ឋមានអត្តសញ្ញាណប័ណ្ណគ្រប់ៗគ្នា ។

**ទី៣** ធ្វើយ៉ាងណាឱ្យយុទ្ធនាការបោះឆ្នោតម្តងៗប្រកបដោយសុវត្ថិភាព ជាយន្តការមួយប្រកបដោយសន្តិភាពអហិង្សា ជាយន្តការមួយដែលអ្នកឈ្នះឆ្នោតឈ្នះនៅក្នុងភាពមិនមានមន្ទិលឈ្នះដោយប្រជាពលរដ្ឋ លោក បោះឱ្យ មិនមែនឈ្នះក្នុងបរិយាកាសភ័យខ្លាច។

## ០៣. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោតថ្លែងដោយ លោក ប្រែង សារុធ ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តកំពង់ធំ

លោក **ប្រែង សារុធ** បានស្វាគមន៍ដល់អង្គប្រជុំទាំងមូល និងសូមថ្លែងអំណរគុណចំពោះ លោក **ឡារី ស្ត្រេន្ទ** នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI ដែលបានអញ្ជើញ លោក ឱ្យចូលរួមក្នុងកិច្ចប្រជុំខមសែសប្រ៉មនេះ ។ លោក បានលើកឡើងអំពីស្ថានភាពជុំវិញការបោះឆ្នោត នៅក្នុងខេត្តកំពង់ធំ ដូចតទៅ:

**ទី១** ការពិនិត្យឈ្មោះ និងការចុះឈ្មោះបោះឆ្នោតកាលពីឆ្នាំ ២០០៦ ដើម្បីបង្កើតបញ្ជីបោះឆ្នោតសំរាប់ឆ្នាំ ២០០៧ ។ ការចុះឈ្មោះ គឺចុះឈ្មោះផង លុបឈ្មោះផង គឺលុបឈ្មោះអ្នកដែលស្លាប់ អ្នកដែលផ្លាស់ប្តូទីលំនៅ និងអ្នកដែលមានទីលំនៅមិនច្បាស់

លាស់ ។ បញ្ហាមួយទៀត ចុះឈ្មោះហើយមិនបានលុបឈ្មោះនេះជាផលពិបាកមួយ ហើយការងារនេះតាមច្បាប់ក្រុមប្រឹក្សាឃុំសង្កាត់រៀបចំបោះឆ្នោតជាអ្នកទទួលខុសត្រូវលើបញ្ជីបោះឆ្នោត ។ ប្រជាពលរដ្ឋសរុបនៅក្នុង ខេត្តកំពង់ធំ មានចំនួន ៦៣៨២៨៤នាក់ ប្រជាពលរដ្ឋដែលមានអាយុ ១៨ឆ្នាំឡើងចំនួន ៣៥០១៧៦នាក់ ហើយអ្នកមានឈ្មោះត្រូវបោះឆ្នោតក្នុងឆ្នាំ ២០០៧ មានដល់ទៅចំនួន ៣៦២៨៥១នាក់ នេះជាតួលេខដែលបានមកពីក្រុមប្រឹក្សាឃុំសង្កាត់រៀបចំកាបោះឆ្នោត តួលេខនេះមានភាពមិនប្រក្រតីព្រោះអ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងអ្នកមានអាយុ ១៨ឆ្នាំឡើង ជាក់ស្តែងប្រជាពលរដ្ឋ ៣១០០០នាក់ មិនទាន់បានចែកប័ណ្ណព័តិមាន លើកទី១ ការចែកប័ណ្ណបានតែ ៨១% លើកទី២ ចែកបាន ៩៤% ។ ក្នុង ៣១០០០នាក់នេះ អ្នកផ្លាស់ប្តូទីលំនៅ ៤០០០នាក់ជាងអ្នកមានឈ្មោះស្ទួន ៣០០០នាក់ជាង អ្នកស្លាប់ ២០០០នាក់ជាង អ្នករកមិនឃើញឈ្មោះ ១៨០០០នាក់ជាង ។ លោក បានបញ្ជាក់ថាឈ្មោះទាំងអស់មាននៅក្នុងការិយាល័យ ៦០០ការិយាល័យជាងទេ ឥលូវកើនឡើងដល់ ៧០៨ការិយាល័យ នៅក្នុង ៨១ឃុំ ។

**ទី២** ការចែកប័ណ្ណព័តិមានដែលបានធ្វើនៅក្នុងខេត្តកំពង់ធំ និងនៅទូទាំងប្រទេស ។ លោក បានមានប្រសាសន៍ថា ការចែកប័ណ្ណព័តមាននេះមាន ៣ដំណាក់កាលរួចហើយ ការសាកល្បងចែកប័ណ្ណព័តិនេះមានតែ ១០ខេត្ត-ក្រុង ក្នុងនោះយកតែ ១ឃុំ ។ លើកទី១ នេះ យកឃុំឈើក្រាល ឃុំនេះការចែកប័ណ្ណលើកដំបូងបាន ៩៧% លើកទី២ នៅខែសីហាបានតែ ៨១% ទេ និង លើកទី៣ ចែកបាន ៩១% ។ ប័ណ្ណព័តមាននេះ នឹងប្រាប់ព័តិមានដល់អ្នកបោះឆ្នោត ព្រោះប័ណ្ណនេះយកចេញពីបញ្ជីឈ្មោះបោះឆ្នោត ប័ណ្ណព័តិមានប្រើសំរាប់ផ្ទៀងផ្ទាត់ នឹងអត្តសញ្ញាណរបស់អ្នកទៅបោះឆ្នោតត្រឹមត្រូវទើបអាចបោះឆ្នោតបាន តែពេលដែលផ្ទៀងផ្ទាត់ នឹងបញ្ជីបោះឆ្នោតមិនត្រឹមត្រូវដោយសារការសរសេរអក្សរ សរសេរដោយដៃមានភាពលំបាកដូចជា អក្សរ ក ទៅ គ ឬ ង ទៅ ល ។ ប្រជាពលរដ្ឋខ្លះពេលទៅចុះឈ្មោះបោះឆ្នោតសរសេរផ្សេង ដល់ពេលទៅធ្វើអត្តសញ្ញាណប័ណ្ណសរសេរផ្សេង ការដែលឈ្មោះមិនត្រូវគ្នានេះហើយបានជា គជប ចេញទំរង់ ១០១៨ ដែលប្រជាពលរដ្ឋអាចទៅជួប នឹងមេឃុំដើម្បីត្រូវឈ្មោះ នឹងប័ណ្ណព័តិមាន ។

**ទី៣** បញ្ជីឈ្មោះបេក្ខជនគណបក្សនយោបាយ និងអ្នកអង្កេតការណ៍សំរាប់ឆ្នាំ ២០០៧ ។ ការចុះបញ្ជីបេក្ខជននេះនៅក្នុងខេត្តកំពង់ធំមាន ៨គណបក្ស គឺគណបក្សប្រជាជន គណបក្សហ៊្វុន ស៊ិនប៉ិច គណបក្ស សម រង្ស៊ី គណបក្ស ប្រជាជាតិខ្មែរ គណបក្សនរោត្តមរណឫទ្ធ គណបក្សសង្គមជាតិនិយម គណបក្សហង្សតារាចលនាលទ្ធិប្រជាធិបតេយ្យ និងគណបក្ស ប្រជាធិបតេយ្យខ្មែរ ។ នៅឆ្នាំ ២០០២ នៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ខេត្តកំពង់ធំមានតែ ៤គណបក្ស នៅឆ្នាំ ២០០៧ ឡើងដល់ ៨គណបក្ស និងមាន ៥៧៧អសនៈបើប្រៀបធៀប នឹងឆ្នាំ២០០២ ដែលមាន ៥៧៥អសនៈ ។

**ទី៤** ទាកទង និងសកម្មភាពឃោសនាបោះឆ្នោត សកម្មភាពមួយចំនួនរបស់គណបក្សនយោបាយដែលកើតឡើង ១សប្តាហ៍ ។ នៅក្នុងកាឃោសនាបោះឆ្នោតមានគណបក្សធំៗបី ដែលធ្វើសកម្មភាពដង្ហែរក្បួនធំៗមានគណបក្សប្រជាជន គណបក្ស សម រង្ស៊ី និងគណបក្សផ្សេងៗទៀត ដែលធ្វើតាមទ្រង់ទ្រាយតូចៗ ។ ក្នុងពេលដំណើរការឃោសនាបោះឆ្នោតមានបណ្តឹងការទំលាក់ផ្លាកមានពីរករណីទី១ មានគណបក្សមួយទៅទំលាក់ផ្លាកគណបក្សមួយទៀត ឬបំផ្លាញចោល ។ **ទី២** ការទំលាក់ផ្លាកមួយទៀតកើតឡើងដោយសារផ្ទៃក្នុងគណបក្សដោយខ្លួនឯង ដោយសារសមាជិកក្នុងគណបក្សមិនបានចង់ផ្លាកគណបក្សអោយបានស្រួលបួលធ្វើរលំ ។ ករណីមួយទៀត កើតនៅឃុំមានរិទ្ធ ស្រុកសំរោង មានទំនាស់មួយកើតឡើងរវាងមេឃុំ និងគណបក្សដែលធ្វើការឃោសនាបោះឆ្នោតដោយសារគណបក្សនោះបានប្រើសំដីប្រមាថទៅលើមេឃុំថា មេឃុំពុករលួយ លក់ដី លក់ប្រជាជន មេឃុំមិនបានមកប្តឹងគណកម្មាធិការរៀបចំការបោះឆ្នោតទេ បែរជាទៅប្រឈមុខគ្នាដោយផ្ទាល់ នឹងគណបក្សនយោបាយដែលប្រើសំដីប្រមាថគាត់ ។ ការឃាសនាលើកនេះមិនសូវជាមានបញ្ហាច្រើនទេ ដោយសារទាំងគណបក្សនយោបាយ សង្គមស៊ីវិលយល់ដឹងច្រើនពីនិតិវិធី នៃការរៀបចំការបោះ

ឆ្នោត មន្ត្រីបោះឆ្នោតបានទទួលការបណ្តុះបណ្តាលពី គជប ។ លោក មានការបារម្ភត្រង់គណបក្សយល់ពីនិតិវិធីតែនៅថ្នាក់ក្រោយមិនសូវបានយល់ មួយទៀតទាក់ទងនឹងអ្នកអង្កេតការណ៍ត្រូវទទួលការបណ្តុះបណ្តាលអោយបានត្រឹមត្រូវ បើមិនដូចនេះទេ អាចធ្វើខុសនិងនិតិវិធី និងអាចបង្កជាបញ្ហានៅក្នុងការិយាល័យបោះឆ្នោត ។ សន្តិសុខមានសភាពល្អប្រសើរជាងពេលកន្លងទៅ ។

លោក **ឱក សេរី សោភក្តិ** កោតសរសើរចំពោះការរីកចំរើននៅ ខេត្តកំពង់ធំ បើប្រៀបធៀបនឹងការបោះឆ្នោតឆ្នាំកន្លងមក លោក បានសំណូមពរអោយអង្គប្រជុំលើកឡើងពីចំនុចឯកភាព និងមិនឯកភាព ដែល លោក ប្រធាន PEC បានលើកឡើង ។

### ០៤. មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការប្រឈមនានាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទ ខេត្តកំពង់ធំ

លោក **គីម អាន** ស្នងការដ្ឋាន ខេត្តកំពង់ធំ បានលើកឡើង ៣ចំនុច **ទី១** ទាក់ទង នឹងការចុះឈ្មោះបោះឆ្នោត ការចែកបណ្ណព័ត៌មាន ដែលមានការខុសច្រើន តែបណ្ណព័ត៌មានចែកក្រោយអោយកែត្រង់ចំណុចដែលមានកំហុសនៅតែមិនកែ តាមការសន្និដ្ឋានរបស់ លោក ដោយសារការភ័ណ្ឌច្រលំខ្លះនៅគណកម្មាធិការរៀបចំការបោះឆ្នោត ដែលមិនបានពិនិត្យអោយបានច្បាស់លាស់ ។ **ទី២** ការឃោសនាបោះឆ្នោត គជប បានផ្តល់វគ្គបណ្តុះបណ្តាលស្តីពីក្រមសីលធម៌ តែនៅតែមានគណបក្សមួយចំនួនមិនគោរពក្រមសីលធម៌ គឺនឹកឃើញពេលណានិយាយតែម្តង ដូចជាថា មេឃុំពុករលួយ លក់ដី កាប់ព្រៃឈើ ជាដើម ។ **ទី៣** ដើម្បីអោយរលូនក្នុងការបោះឆ្នោតបើសិនជាធ្វើបាន សូមអោយភ្នាក់ងារ គជប តាមជាប់ជាមួយអ្នកឃោសនា បើសិនជាឃោសនាខុសសូមអោយកែភ្លាមកុំអោយមានការប៉ះទង្គិចគ្នារវាង គណបក្ស និងគណបក្សទាន់ ។ សំណូមពរមួយទៀតចំពោះពាក្យសំដីមិនសមរម្យ អ្នកខ្លះថា ខ្លួនស្រវឹងនៅពេលដែលនិយាយសំដីមិនសមរម្យនៅទីសាធារណៈ តែពេលមកសារភាពមកតែពីរនាក់ ពេលនិយាយប្រជាពលរដ្ឋបានដឹងទាំងអស់ ដូចនេះសំនូមពរអោយពេលសារភាពដាក់មេក្រូដែរ ដើម្បីប្រាប់ទៅប្រជាពលរដ្ឋថា បានឃោសនាខុសនៅថ្ងៃមុន ។

លោក **នឹង យត** គណបក្ស សម រង្ស៊ី បានលើកឡើងពីចំណាប់អារម្មណ៍របស់ លោក ទាក់ទងនឹងរបាយការណ៍របស់ លោក **ប្រែង សារុធ** ដែលបានលើកឡើងពីដំណើរការណ៍ឃោសនាបោះឆ្នោតមានភាពរលូនល្អ នេះបញ្ជាក់ពីឆន្ទៈរបស់ លោក ដែលចង់អោយដំណើរការនេះប្រព្រឹត្តិទៅដូចនេះប្រាកដមែន ។ លោក បានបន្តថា ចំនុចមួយចំនួនដែលកើតឡើងនៅក្នុងមូលដ្ឋានរបស់ លោក កន្លងមកមានសភាពមិនល្អប្រសើរទេ បើបន្តដូចនេះនឹងធ្វើអោយការបោះឆ្នោតប្រព្រឹត្តនឹងទៅដោយគ្មានតម្លាភាពទេ គ្មានទេលទ្ធិប្រជាធិបតេយ្យ ។ ការងារចុះឈ្មោះបោះឆ្នោតជាការងាររបស់ គជប ដែលបានដាក់ការងារទៅ PEC ហើយទំលាក់បន្តទៅអោយឃុំនៅពេលទៅដល់ឃុំ ស្មៀនឃុំជាអ្នកចុះបញ្ជីឈ្មោះបោះឆ្នោតថ្មីចំពោះអ្នកដែលមានអាយុ ១៨ឆ្នាំ និងអ្នកមិនទាន់មានឈ្មោះបោះឆ្នោត តែពេលនៅឃុំ លោក មេឃុំបានទំរង់ ១០១៨ គាត់យកទៅចុះហត្ថលេខា និងបោះត្រា រួចចែកអោយប្រធានភូមិនេះ ៣០ ប្រធានភូមិនោះ ៣០ ដើរចែកដោយសេរី ពេលល្ងាចឡើងគាត់យកមកអោយស្មៀនឃុំប្រមូលឈ្មោះចុះក្នុងបញ្ជីបោះឆ្នោតចេញទំរង់ ១០១៨ លោក មិនទទួលយកទេធ្វើបែបនេះទេ ។ ការចែកប័ណ្ណព័ត៌មានប្រធានឃុំភាគច្រើនមិនបានចែកប័ណ្ណព័ត៌មានទេ ដល់ថ្ងៃចុះឈ្មោះគាត់ទៅអង្គុយនៅការិយាល័យបោះឆ្នោត បើគាត់មើលទៅជនណាទំរង់ជាសកម្មជនរបស់គណបក្សគាត់ គាត់ចែកអោយ បើជនណាមិនមែនគណបក្សគាត់ គាត់ថា បាត់ហើយ ។ តាមរយៈការឃោសនារយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះ បើពិនិត្យនៅតាមឃុំមានប្រជាពលរដ្ឋពី ៦០% ទៅ ៨០% មិនមានសិទ្ធទៅបោះឆ្នោត ដោយមិនមានអត្តសញ្ញាណប័ណ្ណ និង ទំរង់ ១០១៨ ។ តាម លោក ប៉ាន់ស្មានប្រជាពលរដ្ឋដែលគ្មានឯកសារអត្តសញ្ញាណប័ណ្ណសំរាប់ធ្វើការបោះឆ្នោតពី ២០ ទៅ ៣០% ។

លោក **ស៊ន់ សេក** ជំទប់ទី១ ស្រុកកំពង់ស្វាយ ឃុំសានគរ គណបក្ស ហ៊្វុន ស៊ិនប៉ិច បានលើកឡើងទាក់ទង នឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត **ទី១** ពេលវេលានៃការចុះឈ្មោះខ្លីពេកធ្វើអោយប្រជាពលរដ្ឋមិនអាចចុះឈ្មោះអស់បាន ។ **ទី២** ព័ត៌មានផ្សព្វផ្សាយមិនបានគ្រប់គ្រាន់ទៅដល់ប្រជាពលរដ្ឋ រហូតដល់ចុះឈ្មោះប្រជាពលរដ្ឋមិនដឹងអ្វីថា បញ្ជីកំណើត ឯបញ្ជីកំណើតគ្មានប្រក្រតីភាពដែរហាក់ដូចជាមិនមានសុពលភាពបញ្ជីកំណើតបានត្រឹមត្រូវ ពេលប្រជាពលរដ្ឋយកសំបុត្រកំណើតទៅធ្វើអត្តសញ្ញាណប័ណ្ណ ឬធ្វើទំរង់ ១០១៨ ពេលនោះមិនត្រូវ នឹងអត្តសញ្ញាណប័ណ្ណ ដោយសារសៀវភៅគ្រួសារ និងអត្តសញ្ញាណប័ណ្ណមិនត្រូវគ្នាទាំងបី ព្រោះបញ្ជីអត្រានុគោលដ្ឋានមិនត្រឹមត្រូវ ដូច្នេះការផ្តល់បញ្ជីដល់ប្រជាពលរដ្ឋមិនគ្រប់គ្រាន់ទេ ។ ការពិនិត្យឈ្មោះ និងការកែតំរូវឈ្មោះមានបញ្ហារហូតដល់ពេលនេះទំរង់ ១០១៨ មិនមានគ្រប់ដើម្បីជូនប្រជាពលរដ្ឋទេ ទៅជាគណបក្សអ្នកធ្វើទៅវិញ ។ នៅឃុំសានគរគ្រប់គណបក្សមានការអធ្យាស្រ័យល្អជាមួយគ្នាគោរពឆន្ទៈប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋគ្រប់អាយុបោះឆ្នោតមាន ៨០២៧នាក់ ឈ្មោះអត់បានចែកព័តមានដល់ដៃមានប្រហែល ៧០០នាក់ ។

លោក **ហ៊ុន យ៉ន** ជំទប់ទី១ ឃុំអាចារ្យលាក់ គណបក្ស សម រង្ស៊ី បានមានប្រសាសន៍ថា ការធ្វើបញ្ជីបោះឆ្នោតមានភាពច្បាស់សាល់ល្អ ទោះត្រង់ថា មានការគូសចំណាំថា គ្រួសារនេះមានអ្នកណាដង្ហែទៅគណបក្សណាគូសលប់ចេញ លោក សំណូមពរកុំអោយគូសចំណាំថា អ្នកណាហែគណបក្សណា វាជារឿងមួយមិនល្អ ជាការបិទសិទ្ធសេរីភាពប្រជាពលរដ្ឋ ។

លោក **ប្រែង សារ៉ុផ** បានបញ្ជាក់បន្ថែមទៅលើកិច្ចសហប្រត្តបត្តិការណ៍រៀបចំការបោះឆ្នោត លោក បានទទួលឯកសារមួយចំនួនពាក់ព័ន្ធទៅ នឹង លោក **គីម អាន** ស្នងការដ្ឋាន ខេត្តកំពង់ធំ ដែលបានលើកឡើង ។ ការកែឈ្មោះសាម៉ីខ្លួនបានទៅកែជាមួយនឹងស្មៀនឃុំ ពេលឈ្មោះនោះបញ្ជូនត្រលប់មកវិញមិនមានកែ លោក បានធ្វើការស្រាវជ្រាវ ។ ទាក់ទង នឹងបញ្ហានេះច្រើនដោយដាក់ជាកញ្ចប់តែមួយ លោក បានផ្ទៀងផ្ទាត់បញ្ជីដែលកែជាមួយ នឹងបញ្ជី គជប ការចុះឈ្មោះមិនមែន ជាការងាររបស់ PEC គ្រាន់តែជាអ្នកយកឯកសារពីក្រុមប្រឹក្សាឃុំសង្កាត់រៀបចំការបោះឆ្នោតទៅអោយ គជប ពេលដែលមានបញ្ហាកើតឡើង PEC បានស្រាវជ្រាវរហូតដល់ផ្ទៀងជាមួយកូនបញ្ជីរបស់ស្មៀនឃុំ ។ ស្មៀនឃុំក្នុងការចុះឈ្មោះបោះឆ្នោតមានសៀវភៅបីក្បាល គាត់ត្រូវចំលងអោយបានគ្រប់បីក្បាល តែពេលគាត់ចុះនៅក្បាលទី១ ពេលមានការកែតំរូវគាត់ចុះកែតំរូវ គាត់មិនបានចុះសៀវភៅទី២ ទី៣ គាត់ថា ចាំចប់ចាំចុះចូល ឃុំខ្លះនៅសៀវភៅក្បាលទី១ មានកែតំរូវ ដល់សៀវភៅក្បាលទី២ ទី៣ មិនមានការកែតំរូវ នៅពេលបញ្ជូនទៅ គជប កែតំរូវគាត់បញ្ជូនក្បាលដែលមិនបានកែទៅ នេះពាក់ព័ន្ធស្មៀន និងក្រុមប្រឹក្សាឃុំ ។ លោក បានសំណូមពរអោយពេលកែតំរូវនៅសៀវភៅទី១ ហើយសូមយកទៅកែតំរូវយកតែម្តង ។ មួយទៀតការកែតំរូវមិនមែនអាចកែតំរូវបានទាំងដុលបានទេ គឺបានចំណុចមួយចំនួនដែលមានកំហុសបន្តិចបន្តួចដូចជា អក្សរ ក ទៅជា គ ។ គជប បានចេញលេខ ១៣១បញ្ជូនទៅក្រុមប្រឹក្សាឃុំ-សង្កាត់រៀបចំការបោះឆ្នោត ទៅ PEC និង ការិយាល័យបោះឆ្នោត ក្នុងករណីខុសដែលបានចែងនៅក្នុង ១៣១អាច អោយគាត់បោះឆ្នោតបាន លោក សុំអធ្យាស្រ័យនូវកង្វល់ដែលបានលើកឡើង ហើយមានកំហុសមួយចំនួនខុសខ្លាំងពេលមិនអាចចេញ ទំរង ១០១៨ អោយបាន ដូចជាភេទប្រុសទៅជាភេទស្រី ករណីបើស្រីទៅប្រុស ប្រុសទៅជាស្រីអាចទៅមើលទិន្នន័យមួយចំនួនមានទៀតបើត្រូវភាគច្រើនអោយពួកគាត់បោះឆ្នោតទៅ លោក នឹងយកចំណុចនេះទៅពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ ទៅជួបជាមួយ គជប ដើម្បីសំរួលកែតំរូវដល់ការបោះឆ្នោតឆ្នាំ ២០០៨ ។ ទាក់ទង នឹងការឃោសនារំលោភសិទ្ធ លោក សុំមិនលើកឡើងទេព្រោះជារឿងរបស់គណបក្សនយោបាយត្រូវយល់ពីក្រមសីលធម៌ តែដំណើរការនៃការឃោសនាបោះឆ្នោតមានសភាពល្អប្រសើរបើប្រៀបធៀប នឹងពេលកន្លងមក លោក សូមអោយតាមដានសកម្មភាពការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយដោយ គជប និង CEC ការលំបាក

នោះ គឺ CEC មាន ៥នាក់ឯការឃោសនាធ្វើឡើងនៅច្រើនកន្លែង ពេលគណបក្សនយោបាយធ្វើការឃោសនា CEC ជាប់ទទួលការបណ្តុះបណ្តាលទាក់ទង នឹងការងារបោះឆ្នោត ។ លោក សូមឆ្លើយតម នឹងអ្វីដែលខាងគណបក្ស សម រង្ស៊ី និង ហ៊ុន ស៊ិនប៊ិច លើកឡើងថា ការចុះឈ្មោះប្រព្រឹត្តទៅមានភាពមិនប្រក្រតី ដោយសារការចុះឈ្មោះបោះឆ្នោតមិនសុក្រឹតមិនរលូន ពាក់ព័ន្ធនឹងការចែកប័ណ្ណព័ត៌មាន ជាការដកពិសោធន៍លើកដំបូង លើកទី១ មេឃុំ និងមេភូមិមិនមានសិទ្ធិមកពាក់ព័ន្ធ នឹងការបែងចែកប័ណ្ណព័ត៌មានទេ ក្រែងពាក់ព័ន្ធនឹងបញ្ហាថាលំអៀង អាជ្ញាធរមិនយុត្តិធម៌ចែករើសមនុស្ស លើកទី២ និងទី៣ អោយមេឃុំ មេភូមិចែកប័ណ្ណព័ត៌មាន ដោយសារគាត់ស្គាល់ ភូមិ ឃុំ និងសមាសភាពប្រជាពលរដ្ឋជាក់លាក់ដើម្បីអោយព័ត៌មានបានដល់ដៃប្រជាពលរដ្ឋ ។ ការចែកប័ណ្ណព័ត៌មានជូនកាលមេឃុំ មិនចែកអោយដោយសារការចែកប័ណ្ណធ្វើឡើងតាមភូមិ និងក្រុមនិមួយ នៅពេលក្រុមថ្ងៃទី១ ទៅចែកនៅភូមិ១ ភូមិមួយទៀតមិនទាន់បានចែក ជូនកាលប្រជាពលរដ្ឋដឹងថា ចែកនៅភូមិគេ ភូមិគាត់មិនចែកគាត់គិតថា ការចែកប័ណ្ណលំអៀងចែកតែក្រុមគណបក្សគ្នាគេ តែជួនកាលមានក្រុមប្រឹក្សាឃុំមួយចំនួនទៀតលំអៀងធ្វើមិនត្រឹមត្រូវ ទន្ទឹមនឹងនោះគាត់ថា កម្មវិធីមិនទាន់ដល់ ដូចនេះជាកំហុសរបស់ក្រុមប្រឹក្សាឃុំដែលមិនបានជូនដំណឹង កម្មវិធីចែកប័ណ្ណដល់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំធ្វើការមិនបានជិតដល់ លោក សូមអោយមានការកែលំអរ ។ លោក បានបន្តថា ប្រជាពលរដ្ឋ ៩០% សុំធ្វើទំរង់ ១០១៨ ពេលនោះ លោក ចេញអោយជំទប់អោយក្រុមប្រឹក្សាឃុំ ឬមេឃុំថ្ងៃបោះឆ្នោតយកត្រាមកផង ទំរង់ ១០១៨ មកផង ដើម្បីជំរុញអោយការបោះឆ្នោតប្រព្រឹត្តទៅបានល្អ ។ លោក សំណូមពរអោយខាងផ្នែកស្នងការនគរបាល ចែកអត្តសញ្ញាណប័ណ្ណដែលនៅក្នុងដៃដល់ប្រជាពលរដ្ឋអោយអស់រហូតដល់មេឃុំនៅ CEC លោក ត្រូវដឹងថា នៅកន្លែងណាមិនចែកអត្តសញ្ញាណប័ណ្ណដល់ប្រជាពលរដ្ឋរាយការណ៍ដល់ លោក ស្នងការហើយខាងក្រុមប្រឹក្សាឃុំត្រូវបន្តផ្តល់ទំរង់ ១០១៨ ដល់ប្រជាពលរដ្ឋអោយបានអស់ បើមិនអស់ទេប្រយ័ត្នប្រជាពលរដ្ឋប្តឹងក្រុមប្រឹក្សាឃុំពិតជាមានបញ្ហាធំ ។ ពាក់ព័ន្ធ នឹងការចុះឈ្មោះបោះឆ្នោតមានរយៈពេលវែងគ្រប់គ្រាន់ បើហ៊ានតែពន្យាពេលវែងក៏រិតណា គឺយើងចំណាយកាន់តែច្រើនក៏រិតនោះ ហើយក៏រិតនៃការចុះតែប៉ុណ្ណឹង ដូចនេះតាមច្បាប់អោយចុះតែ ២០ថ្ងៃ គឺពីថ្ងៃ ១ ដល់ ថ្ងៃ ២០ ខែ តុលា ហើយ គជប ក៏បានថែមពេលអោយ ៤ថ្ងៃទៀត ទោះបីជាពន្យាទៀត បើគាត់មិនចង់មកចុះឈ្មោះគាត់នៅតែមិនមកដដែល ហើយទំរង់ ១០១៨ គ្មានរូបថតគ្មានសុពលភាពមិនអាចយកទៅបោះឆ្នោតបានទេ នៅខេត្តកំពង់ធំគណបក្សភាគច្រើនផ្តល់លទ្ធភាពក្នុងការថតរូបអោយប្រជាពលរដ្ឋ ។ ពាក់ព័ន្ធនឹងការចេញអត្រានុគោលដ្ឋាន អានាធិបតេយ្យ លោក សុំមិននិយាយទេ ព្រោះជាការងាររបស់ក្រុមប្រឹក្សាឃុំ ។

លោក **ឪក សេរី សោភក្តិ៍** បានមានប្រសាសន៍ថា បញ្ហាដែលបានលើកឡើង គឺស្ថិតនៅក្នុងរង្វង់ការទទួលខុសត្រូវពីរ ។ **ទី១** ការទទួលខុសត្រូវរបស់អាជ្ញាធរ និងសមត្ថកិច្ចនៅក្នុងថ្នាក់មូលដ្ឋាន ដូចនេះកិច្ចការទាក់ទង នឹងតួនាទីរបស់ក្រសួងមហាផ្ទៃដែល នឹងត្រូវរាយការណ៍ទៅថ្នាក់ជាតិព្រោះរឿងនេះមិនមែនជារឿងប្លែកពីខេត្តឯទៀតទេ ការបំពេញតួ នាទីនៅមានការខ្វះចន្លោះតាំងពីស្ថិតិប្រជាពលរដ្ឋដោយបញ្ជីឈ្មោះប៉ោង អោយទៅថ្នាក់ជាតិខ្វះចន្លោះដល់ទៅ ៦០% ទៅ ៧០% មិនមែនជារឿងធម្មតាទេ ការដែលស្មៀនឃុំមិនបានកែ ឱ្យមានភាពច្បាស់លាស់ លោក គិតថា គួតែមានសន្និសិទ្ធថ្នាក់ជាតិ ទាក់ទងរឿងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ និងស្មៀនឃុំដើម្បីធ្វើការកែប្រែ បើមិនដូចនេះទេការទទួលខុសត្រូវ នឹងជះឥទ្ធិពលដល់បញ្ជីឈ្មោះបោះឆ្នោត តាំងពីរឿងអត្រានុគោលដ្ឋាន ការដូរឈ្មោះមិនបានលុបឈ្មោះចេញ និងបញ្ហាអត្តសញ្ញាណប័ណ្ណជាដើម ។ **ទី២** លោក គិតថា ល្មមដល់ពេលមួយដែលប្រជាពលរដ្ឋខ្លួនឯងត្រូវចូលរួមជាមួយគ្នាដើម្បីអប់រំប្រជាពលរដ្ឋអោយស្គាល់ពីបេក្ខភាពរបស់ខ្លួនឯងក្នុងការចុះឈ្មោះ ការកែឈ្មោះ

ត្រឹមត្រូវ ទាល់តែប្រជាពលរដ្ឋចូលរួមទើបអាជ្ញាធរប្រយ័ត្នប្រយែង បើនៅតែពឹងផ្អែកទាំងស្រុងទៅលើ អាជ្ញាធរនឹងនៅតែមានខុសតទៅទៀត ។

លោក **ទង លាវ** ក្រុមប្រឹក្សាឃុំ អាចារ្យលាក់ គណបក្សប្រជាជន សំណូមពរអោយក្រុមប្រឹក្សាឃុំ-សង្កាត់ គ្រប់គណបក្សទាំងអស់លើកឡើងពីបញ្ហាអ្វីខ្លះដែលយើងត្រូវចែករំលែកគ្នាទៅវិញទៅមក ។ លោក សូមរំលឹកឡើងវិញពីតួនាទីរបស់មេឃុំ គឺនៅផ្ទាល់ជាមួយប្រជាពលរដ្ឋ ប្រជាពលរដ្ឋគ្រប់រូបត្រូវទាក់ទងផ្ទាល់ជាមួយ នឹងអាជ្ញាធរស្រុក ខេត្ត ជាពិសេសក្រសួងមហាផ្ទៃ ដែលត្រូវអប់រំ ប្រជាពលរដ្ឋអោយបំពេញតួនាទីរបស់ខ្លួនជាប្រជាពលរដ្ឋមិនត្រូវពឹងផ្អែកទាំងស្រុងលើតែអាជ្ញាធរទេ ។

លោក **ស៊ីន សិប** អភិបាលរងខេត្តកំពង់ស្ពឺយមានមតិបំភ្លឺអំពីប័ណ្ណព័ត៌មាន និងបញ្ហាដែលកើតមានឡើងនៅក្នុងភូមិអាចារ្យលាក់ ។ ប័ណ្ណព័ត៌មានក្រុមប្រឹក្សាឃុំរបស់ លោក បានចែកជាមួយ PEC បានប្រមូលគ្រប់គណបក្សនយោបាយទាំងអស់ដើម្បីចូលរួម និងចែកជូននូវកម្មវិធីត្រូវចែកនៅភូមិណាប៉ុន្មានថ្ងៃ ។ ការលុបឈ្មោះពីបញ្ជី មិនមែនលុបឈ្មោះក្នុងបញ្ជីបោះឆ្នោតទេដោយសាមានសមាជិកសុំចុះចូលពេលហែរ គឺហែរគណបក្ស អ្នកដែលមិនមកលុបឈ្មោះចេញ លោក សុំកុំអោយយល់ច្រលំថា លុបឈ្មោះពីបញ្ជីបោះឆ្នោត ។ ប័ណ្ណព័ត៌មាន លោក ចែកជូនទាំងអស់មិនប្រកាន់ថា គណបក្សណាឡើយ មានការអនុគ្រោះគ្នាទៅវិញទៅមក ។

លោក **សុខ ប៉េងសេង** សមាជិកក្រុមប្រឹក្សាស្រុកកំពង់ស្ពឺយ គណបក្ស សម រង្ស៊ី បានមានប្រសាសន៍ថា លោក ស្តាប់មិនច្បាស់ លោក គិតថា ក្រុមប្រឹក្សាឃុំសង្កាត់បើគ្មានអ្នកនឹងទៅហែក្បួនត្រូវលុបឈ្មោះបញ្ជីបោះឆ្នោត តែខាង គណបក្ស ប្រជាជនបញ្ជាក់ថា មិនមែនទេដោយសារមនុស្សទាំងនោះចូលក្នុងគណបក្សគេហើយ ដូច្នេះត្រូវលុបឈ្មោះពីគណបក្សដើមចេញ នេះសរបញ្ជាក់អោយឃើញថា ការដែលយើងធ្វើការពិភាក្សានេះផ្តល់ឱកាសអោយដើម្បីបញ្ជាក់ពីចំងល់ទាំងឡាយអោយយល់ច្បាស់ទាំងអស់គ្នានេះជាការប្រសើរណាស់ ។

លោក **គីម អាន** បានមានប្រសាសន៍ថា លោក បានស្តាប់វាលគ្និនមួយចំនួនបានមានយោបល់ជាច្រើន ភាគច្រើនទំលាក់កំហុសទៅលើក្រុមប្រឹក្សាឃុំ និងភូមិ ក្នុងនាម លោក ជាអភិបាលស្រុកថ្មីត្បិត លោក មិនអនុវត្តន៍ផ្ទាល់ក៏ដោយ លោក អភិបាលខេត្តបានអោយ លោក តាមដាននូវការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំសង្កាត់ ត្រឹមត្រូវតាមច្បាប់ និងការណែនាំរបស់រដ្ឋាបាលក៏ដូចជាក្រសួងមហាផ្ទៃ តាមការតាមដានរបស់ លោក ភាគច្រើនការអនុវត្តន៍របស់ឃុំបំពេញពាក្យអោយប៉ូលិសខេត្ត ឯប៉ូលិសខេត្តចេញទៅអនុវត្តន៍ ។ កត្តាដែលសំខាន់ជាងគេ គឺការផ្តល់អត្តសញ្ញាណប័ណ្ណអោយប្រជាពលរដ្ឋមានសិទ្ធពេញលេញក្នុងការ ចូលរួមបោះឆ្នោត ។ ដើម្បីអោយប្រជាពលរដ្ឋអាចទៅបោះឆ្នោតបាន នគបាលជាអ្នកផ្តល់អត្តសញ្ញាណប័ណ្ណ ក្នុងករណីមិនមានអត្តសញ្ញាណប័ណ្ណក្រុមប្រឹក្សាឃុំតាមច្បាប់ត្រូវចេញទំរង់ ១០១៨ ដល់ប្រជាពលរដ្ឋ តែក្នុងការធ្វើនេះក្រុមប្រឹក្សាឃុំ និងស្មៀនមាន ការលំបាកត្រង់ចំណុចនេះចំពោះប្រជាពលរដ្ឋមានអត្តសញ្ញាណប័ណ្ណពេលទៅផ្ទៀង នឹងបញ្ជីខុសពីបញ្ជីទៅទៀត ដូចនេះអត្តសញ្ញាណ ប័ណ្ណនេះទុកសិនមិនអាចប្រើបានទេ មេឃុំត្រូវចេញទំរង់ ១០១៨ អោយប្រជាពលរដ្ឋ ការធ្វើនេះមានការស្មុគស្មាញ ២ ដែល លោក បានឃើញ ។ **ទី១** ទំរង់ ១០១៨ មិនបានផ្តល់អោយគ្រប់ទេ ពេលថតពេលមិនមានលុយ លោក ចេញលុយផ្ទាល់ខ្លួនអោយអស់មួយ ចំនួនធំ ។ **ទី២** ពលរដ្ឋទៅធ្វើចាំបាច់បែបបទទាំងអស់ ត្រូវមានរូបថត ព្រោះពេលគាត់ទៅ គាត់មិនមានរូបថត ដូចនេះហើយស្មៀនមិនធ្វើអោយទេ ដោយអោយពួកគាត់ត្រលប់ទៅយករូបថតវិញ ព្រោះបើចេញទំរង់ ១០១៨ អោយហើយគ្មានរូបថតក៏គ្មានសុពលភាពដែរ ដូចនេះហើយបានមានការចោទថា ស្មៀនមិនធ្វើទំរង ១០១៨ អោយ ។ នេះជាការលំបាករបស់ស្មៀនឃុំ ដែលគាត់តែម្នាក់ឯង ឯប្រជាពលរដ្ឋមានច្រើន

ឃុំខ្លះមានរហូតទៅដល់ ២២ភូមិ ប្រជាពលរដ្ឋរាប់ម៉ឺននាក់មិនងាយដើរបញ្ជូនម្នាក់ៗបានទេ ។ មួយទៀតការបន្ទោសអាជ្ញាធរមិនប្រមូលប្រជាពលរដ្ឋអោយចូលរួមឃោសនា នេះ ជាសិទ្ធរបស់ប្រជាពលរដ្ឋយើងមិនអាចបង្ខំគាត់បានទេ ។

លោក **សុខ ប៉េងសេង** បានបន្ថែមទាក់ទង នឹងអ្វីដែល លោក ស្នងការលើកឡើងថា បើពេលឃោសនា គណបក្ស និងគណបក្សមានការផ្សាយមានការប៉ះពាល់គ្នាអោយផ្សាយជាសាធារណៈ តែតាម លោក ពិនិត្យមើលទៅ និងនិតិវិធីរបស់ គជប ត្រូវធ្វើការប្តឹងផ្តល់បើកសាវនាការប្រជុំបក្ស បើលោកស្នងការអោយធ្វើដោយបើកចំហរដូចជាខុស នឹងនិតិវិធីបន្តិច ។ មួយទៀតទាក់ទងនឹងប្រសាសន៏លោកស្នងការដែរ គឺការធ្វើអត្តសញ្ញាណប័ណ្ណធ្វើតាំងពីខែកញ្ញាមុនពេលចុះឈ្មោះបោះឆ្នោតតែ រហូតមកដល់ពេលនេះមិនទាន់បានចែកជូនប្រជាពលរដ្ឋ លោក សូមអោយលោកស្នងការពិនិត្យមើលកន្លែងនេះ ព្រោះកន្លងមកអត្តសញ្ញាណប័ណ្ណធ្លាក់ទៅតាមលំដាប់ ។ ពាក់ព័ន្ធនឹងការការពារបើតាមប្រសាសន៏ លោក **ប្រែង សារ៉ុធ** ការការពារផ្នែកសន្តិសុខ មានភាពរលូនល្អនៅក្នុងស្រុក លោក សូមឯកភាព ។ ចំពោះ លោក ខាងតំណាងអោយគណបក្ស សម រង្ស៊ី លោក បានធ្វើការឃោសនា ប៉ុន្មានកន្លែងហើយមិនឃើញប៉ូលិសចុះទៅសោះ តែការឃោសនាកន្លងមកល្អមិនមានបញ្ហាអ្វីកើតឡើងទេ ។

លោក **ស៊ន់ សេក** គណបក្សហ្វ៊ុនស៊ិនប៉ិច ទាក់ទង នឹងការធ្វើអត្តសញ្ញាណប័ណ្ណជូនកាលថតហើយមិនឃើញរូប ហើយអត្តសញ្ញាណប័ណ្ណ និងបញ្ជីឈ្មោះអានខុសគ្នា ។ មានអត្តសញ្ញាណប័ណ្ណខ្លះខុសតែម្តងសំខាន់អក្ខរាវិរុទ្ធ ដូចនេះត្រូវធ្វើម្តងទៀត នេះជាការធុញទ្រាន់របស់ប្រជាពលរដ្ឋ ធ្វើអោយខាតពេលវេលារបស់ពួកគាត់ ។ សន្តិសុខការពារ លោក បានបញ្ជាក់ច្បាស់ហើយ តែខាងគណបក្ស ខ្លួនឯងមិនមកទទួលយក បើសិនជាត្រូវការត្រូវមកជួប លោក ចាត់ចែងជូន ។ មួយទៀត លោក បានរក្សាកងកំលាំងតាមផ្លូវ ដើម្បីតាមដានសីលធមិឃោសនា លោក សំណូមពរអោយរក្សាសីលធមិនៃការឃោសនា ដើម្បីជៀសវាងការប៉ះពាល់គ្នាទាំងខាងពាក្យសំដី និងឧបករណ៏ ។

លោក **ឱក សេរី សោភក្តិ៍** បានមានប្រសាសន៏ថា លោក បានជួបជាមួយឯកឧត្តម **ស ខេង** នៅគេហដ្ឋានរបស់ឯកឧត្តម ជាច្រើនដងក្នុងការធ្វើគំរោង COPCEL លោក បានបញ្ជាក់ថា ដោយសារការធ្វើជាមួយក្រុមហ៊ុនចិនទាំងពីរពិបាកពេកមានកន្លែងខ្លះខូចឆេះអស់ ដូច្នេះក្រសួងសំរេចថានានុក្រមពីថ្នាក់ជាតិមកថ្នាក់ខេត្ត នេះជាដំណឹងមួយដែលជាការល្អដើម្បីអោយគៀកនឹងប្រជាពលរដ្ឋផ្ទាល់ ។ ប៉ុន្មានថ្ងៃមុន លោក បានជួបប្រជុំជាមួយ ឯកឧត្តម **អ៊ឹម សូស៊ី** ប្រធាន គជប ឯកត្តមទទួលស្គាល់ពីការលំបាកនៅក្នុងបញ្ជីឈ្មោះបោះឆ្នោតយើងនឹងធ្វើការជាមួយគ្នាដើម្បីដោះស្រាយ និងផ្សព្វផ្សាយចំនេះដឹងរវាងអង្គការផ្សព្វផ្សាយ គជប និងក្រសួងមហាផ្ទៃ ជាមួយក្រុមបច្ចេលទេសដើម្បីដោះស្រាយ ។

លោក **ប្រែង សារ៉ុធ** បានលើកឡើងពីការិយាល័យឃុំសាគរ កន្លងមកភូមិសាគរមាន ១៦ការិយាល័យ ១៦កន្លែង តែឥលូវមានទៅដល់ ១៧កន្លែង ហើយអ្វីដែលជាចំងល់របស់ លោក គឺថាហេតុអ្វីបានជាមិនជុំវិញការិយាល័យទៅអោយគៀកប្រជាពលរដ្ឋ? នៅភូមិមាល័យមានទីតាំងការិយាល័យបោះឆ្នោតជាមួយភូមិអំពិលតែពេលនេះបំបែកគ្នា ការបំបែកនេះការិយាល័យរបស់ភូមិអំពិលនៅដាច់ស្រយាល ដោយត្រូវឆ្លងទឹក ។ ទាក់ទងនិងទំរង់ ១០១៨ លោក សូមបញ្ជាក់ទៅ លោក អភិបាលស្រុកថា បើប្រជាពលរដ្ឋទៅចុះឈ្មោះមិនមានរូបថតទេ មិនចុះឈ្មោះអោយទេ បើលោកមិនច្រលំទេ និតិវិធីរបស់ ជគប ផ្តល់អនុគ្រោះស្មៀនឃុំថា ចុះឈ្មោះក៏ខុសចុះតែសូមអោយប្រជាពលរដ្ឋជ្រើសរើសធ្វើទំរង់ ១០១៨ ទោះបីគាត់មិនមានរូបថតក៏ដោយ ចាំពេលគាត់មានរូបថតទៅបោះទៅរហូតដល់ថ្ងៃបោះឆ្នោត ។ លោក បានឯកភាពដែលថានេះមិនមែនជាកំហុសរបស់មេឃុំ ជាភារកិច្ចរបស់ប្រជាពលរដ្ឋ ពេលដែលគណបក្សប្រជាជនឃោសនា មេឃុំហៅប្រជាពលរដ្ឋមកចូលរួមស្តាប់ បើសិនជាគណបក្សផ្សេង ទោះបីប្រាប់ក៏មេឃុំ

មិនហៅប្រជាពលរដ្ឋមកដែរ ។ លោក បានដឹងថា ក្រុមប្រឹក្សាឃុំ-សង្កាត់ មានការលំបាកតែតាមច្បាប់ រដ្ឋបាលក្រុមប្រឹក្សាឃុំសង្កាត់ បានចែងហើយថា ក្រុមប្រឹក្សាឃុំ-សង្កាត់ មានសិទ្ធរើសជំនួយការបំរុងសំរាប់ជួយមេឃុំ ។

លោក បានលើកឡើងពីទំរង់ ១០១៨ មានសេចក្តីតាមការណែនាំរបស់ គជប បានចេញសេចក្តីណែនាំក្រោយ គឺអោយធ្វើទំរង់ ១០១៨ អោយតែអោយជំពាក់រូបថត តែពេលនេះកៀកថ្ងៃបោះឆ្នោតហើយ អ្នកជំពាក់មិនឃើញមក ឯអ្នកដែលមានខុសឈ្មោះកែអោយថ្មី ក៏មិនឃើញយករូបថតមកទៀត ។

លោក **ឱក សេរី សោភក្តិ៍** បានមានប្រសាសន៏ថា បណ្តាខេត្តដែលបានឆ្លងកាត់ខេត្ត ២៣ទាំងខេត្តកំពង់ធំ បានឃើញថា គណបក្សទាំងអស់ចូលរួមអោយប្រជាពលរដ្ឋហួសហេតុ មិនត្រឹមតែថតរូបអោយ ថែមកូពីទំរង់ ១០១៨ អោយទៀត ហើយ PEC ក៏បានអនុញ្ញាតិអោយធ្វើដែរដើម្បីសំរួលដល់ប្រជាពលរដ្ឋ តែយើងទទួលស្គាល់ថា ទោះបីជាខិតខំធ្វើក៏នៅតែមានខ្វះចន្លោះដោយប្រជាពលរដ្ឋខ្លះមិនទាន់បានទទួលរូបថត លោក គិតថា ការបោះឆ្នោតលើកក្រោយៗទៀតបញ្ហាលំបាកលែងមានហើយបើសិនជាសស្រាកសស្រាំទាំងអស់គ្នាជួយប្រជាពលរដ្ឋទៀត ។

លោក **ប្រែង សារ៉ុធ** បានលើកឡើងពីការភាកិច្ចរបស់ក្រុមប្រឹក្សាឃុំ ក៏ដូចជា CEC ក្នុងដំណើរការបោះឆ្នោតការប្រជុំលើកនេះ លើដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយស្រួល អ្វីដែល យន្តការបង្កាទំនាស់ នេះបានទាញនូវមនោសញ្ចេតនាអោយចេះយោគយល់គ្នាទៅវិញទៅមក ។ ទំរង់ ១០១៨ យើងបានលើកមកពិភាក្សាគ្នាដើម្បីរកដំណោះស្រាយរួមមួយទាំងអស់គ្នាដូចប្រសាសន៏លោកអភិ ស្រុក និងគណបក្សមួយចំនួនបានលើកឡើង បើសិនជាទំរង់ ១០១៨ ខ្វះ លោក តែងតែសំណូមពរទៅគ្រប់ CEC អោយជូនដំណឹងទៅគ្រប់ក្រុមប្រឹក្សាឃុំ ខាង លោក នឹងផ្តល់លទ្ធភាពជួយ លោក បានជួយខ្លះៗហើយ តែមិនបានជួយច្រើនទំរង់ ១០១៨ធ្វើឡើងរហូតដល់ថ្ងៃបោះឆ្នោត អ្វីដែលសំខាន់អ្នកទៅបោះឆ្នោតត្រូវមានអត្តសញ្ញាណប័ណ្ណណាមួយដើម្បីទៅបោះឆ្នោតពិសេសទំរង់ ១០១៨ ព្រោះអត្តសញ្ញាណប័ណ្ណដែលធ្វើមិនត្រូវ នឹងបញ្ជីបោះឆ្នោត ទំរង់ ១០១៨ ត្រូវមានរូបថត និងត្រារបស់មេឃុំ ។ លោក បានធ្វើសេចក្តីអំពាវនាវ រឹតបណ្តឹងទៅលើ សូមអោយធ្វើការថ្លឹងថ្លែងទំរង់ ១០១៨ លុបចេញមានប៉ុន្មានដែលបានបិទរូបថតហើយប៉ុន្មានមិនបានបិតរូបថត ១០១៨ មិនទាន់បិទរូបថតមេឃុំត្រូវរំលឹកដល់ពួកគាត់អោយគាត់ជ្រាប និង គណបក្សដែលមានការពាក់ព័ន្ធ ។ ពាក់ព័ន្ធនឹងអត្តសញ្ញាណប័ណ្ណទោះបីជាមិនត្រូវក៏ដោយ សូមអោយបាន ៥០% នៃចំនួនសរុប រួចហើយសំរួលការខុសបន្តិចបន្តួច ដូចជាថ្ងៃ កំណើត ឆ្នាំកំណើត ខុសភេទ ខុសអក្សរក ទៅអក្សរគ តិចតួចអាចអោយបោះឆ្នោតបានគ្រាន់តែខុសពីបញ្ជីបោះឆ្នោតលុបចោលអត្តសញ្ញាណប័ណ្ណចោល ពេលគាត់មានយកទៅប្រើបានយើងមិនប្រើ ដូច្នេះ លោក សូមអោយក្រុមប្រឹក្សាឃុំ ពិចារណាឡើងវិញ ។ ទាក់ទង នឹងទំនាស់ពេលឃោសនាបោះឆ្នោត លោក ស្នងការសុំអោយធ្វើធូន់បន្តិច ឯខាងគណបក្ស សម រង្ស៊ី សុំថាគួអោយមានការប្តឹងតវ៉ា លោកបានជំរាបថា លោកធ្វើទៅតាមនិតិវិធី និងច្បាប់ដែលបានចែង មិនអាចធ្វើអោយខុសពីនិតិវិធី និងច្បាប់បានទេ ។ ទីតាំងការិយាល័យ លោក សូមបញ្ជាក់ថា មិនបន្ទោសក្រុមប្រឹក្សាឃុំ ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ ចុះឈ្មោះបោះឆ្នោតកំណត់ទីតាំងកិរិយាល័យបោះឆ្នោត ។ រៀងរាល់ឆ្នាំមុនពេលបោះឆ្នោត គជប ជូនដំណឹងទៅក្រុមប្រឹក្សាឃុំអោយពិនិត្យឡើងវិញទីតាំងកែតំរូវការិយាល័យបោះឆ្នោត លោក មិនបន្ទោសក្រុមប្រឹក្សាឃុំទេ ជួនកាលគាត់កំណត់ការិយាល័យមិនត្រឹមត្រូវ កាលណាធ្វើទៅហើយ ចេញមកវិញ គឺយ៉ាងនឹង ការិយាល័យមាន ៧០០នាក់ ដាក់ដល់ទៅ ៧៥០នាក់ សូម្បីតែ ៧០១នាក់ ក៏មិនមានច្បាប់ដែរលោក សូមអោយក្រុមប្រឹក្សាឃុំ សាគរ ពិចារណាឡើងវិញ ព្រោះពាក់កណ្តាល់ខែកញ្ញានេះមានការចុះឈ្មោះបោះឆ្នោតទៀតហើយសំរាប់ការជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៨ បើមានបញ្ហាសូមអោយកែតាមដំណើរដោយឯកភាពតាមក្រុមប្រឹក្សាឃុំដើម្បីបង្ករ

លក្ខណៈងាយស្រួល ព្រោះតាមគោលការណ៍ ការិយាល័យកំណត់មិនអោយហួសពី ៥គីឡូម៉ែត្រ ។ លោក បានបញ្ជាក់ថា ភូមិអំពិល មានការិយាល័យបោះឆ្នោតតែមួយគត់ ហើយមានចំងាយពីក្រុមប្រឹក្សាឃុំ ៧៨គីឡូម៉ែត្រ ពីទីតាំង CEC ដូចនេះហើយត្រូវលើក ការិយាល័យដាក់ទៅតាមកន្លែងរបស់គាត់ បើមិនដូច្នេះទេប្រជាពលរដ្ឋ និងមិនមកបោះឆ្នោតទេ ។ ទាក់ទងអ្នកជំពាក់រូបថតទំរង់ ១០១៨ បើខាងក្រុមប្រឹក្សាឃុំ គណបក្ស មានទំរង់ហើយ អោយជំពាក់មានន័យថា មិនចង់អោយប្រជាពលរដ្ឋទៅបោះឆ្នោត ដែលក្នុង នឹងមានអាជ្ញាធរដែនដី ក្រុមប្រឹក្សាឃុំ និងខាងគណបក្សផងដែរ ដូច្នេះឈប់អោយប្រជាពលរដ្ឋជំពាក់ទៅ ដើម្បីជៀសវាងនាំឱ្យមាន បញ្ហាកើតឡើង។

លោក **ឡារី ស្ត្រេន្ទ** បានមានប្រសាសន៍ថ្លែងអំណរគុណជាថ្មីម្តងទៀតដល់អង្គប្រជុំទាំងមូល ហើយ លោក បានលើកឡើងនូវ ចំណុច ៣

**ទី១** លោកផ្ទាល់មានកិត្តយស និងសេចក្តីសប្បាយរីករាយណាស់ដែលបានអង្គុយនៅកន្លែងមួយ ដែលបង្ហាញពីការកសាង លទ្ធិប្រជាធិបតេយ្យដ៏ចាស់ចិត្តចាស់គំនិត តាមរយៈការពិភាក្សានេះ ។

**ទី២** ជាចំណុចសំខាន់សំរាប់វិទ្យាស្ថាន CDRI និងខប់សែល ថាតើយន្តការអ្វីដែលធ្វើឱ្យមានភាពសុក្រឹត្យនៅក្នុងការចែក ប័ណ្ណព័ត៌មានដល់ប្រជាពលរដ្ឋសំរាប់ពិនិត្យមើល ។ នេះគឺជាចំណុចសំខាន់ ព្រោះជាមូលដ្ឋានមួយ ដើម្បីជំរុញឱ្យមានតម្លាភាពនៅក្នុង ការធានាឱ្យបាននូវការបោះឆ្នោតមួយប្រកបទៅដោយត្រឹមត្រូវ និងយុត្តិធម៌ ជាពិសេសធានាឱ្យមានការឯកភាពគ្នា និងការទទួលខុស ត្រូវរវាងគណបក្សនយោបាយ និងភាគីពាក់ព័ន្ធនានាជុំវិញការងារបោះឆ្នោត ។

**ទី៣** សូមថ្លែងអំណរគុណដល់លោក ឌិក សេរី សោភក្តិ ។ លោកផ្ទាល់មកពីប្រទេសអូស្ត្រាលី ហើយបានធ្វើការនៅប្រទេស កម្ពុជាបានជាង៣ ឆ្នាំ ជានាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI លោកមកពីប្រទេសមួយដែលមានលទ្ធិប្រជាធិបតេយ្យដ៏រឹងមាំ និងយូរ អង្វែង ប៉ុន្តែមុននិងឈានបាននូវការកសាងធម្មនុញ្ញប្រកបដោយលទ្ធិប្រជាធិបតេយ្យរឹងមាំនេះ គឺមានមេរៀនមួយដល្អដែលលោកនឹង ចែករំលែក គឺយើងត្រូវការពេលវេលាយូរអង្វែងណាស់ដើម្បីធ្វើឱ្យបានធម្មនុញ្ញមួយប្រកបដោយលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ស្ថេរ ភាព ហើយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ។ យើងបានព្យាយាមធ្វើមួយជំហានម្តងៗ ដោយមានការចូលរួមយ៉ាងសកម្ម ពីគ្រប់ភាគីពាក់ព័ន្ធ ដូចជាអាជ្ញាធរ អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ ដើម្បីធានាឱ្យបានថាសមិទ្ធិផលទាំងអស់នេះគឺអាចទទួលបាន ទាំងអស់គ្នា ហើយគោរព និងអនុវត្តទាំងអស់គ្នា ។ នេះជាគោលបំណងសំខាន់របស់ខប់សែលដែលចង់បាន ដូចអ្វីដែលយើងទាំងអស់ គ្នាចង់បានដែរ ដូចនៅក្នុងប្រទេសរបស់ លោក ដែរ ។

ជាចុងក្រោយ លោក សូមសំដែងនូវការកោតសរសើរ និងឆន្ទៈនៃការចូលរួមយ៉ាងមុតមាំ និងសកម្មរបស់អង្គប្រជុំនេះ ។ លោកក៏សូមថ្លែងអំណរគុណដល់ លោក ឌិក សេរី សោភក្តិ ដែលបានសំរបសំរួលយ៉ាងប៉ិនប្រសព្វសំរាប់កិច្ចប្រជុំខប់សែលប្រ៊ម និងអរគុណដល់ ក្រុមខប់សែល ដែលបានរៀបចំកិច្ចប្រជុំនេះប្រកបទៅដោយផ្លែផ្កា ជាពិសេសសូមថ្លែងអំណរគុណដល់ UNDP ដែលបានគាំទ្រលើផ្នែក ថវិការទាំងស្រុងលើកម្មវិធីខប់សែលរបស់វិទ្យាស្ថាន CDRI។